ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

ឯកសារ **D381/42 & D382/41**

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

**អង្គបុរេជំនុំជម្រះ**

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទៈ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 18-Mar-2021, 16:00
CMS/CFO: Sann Rada

---

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឲ្យបដិសេធសេចក្តីសម្រេចលើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី**

---

**សហព្រះរាជអាជ្ញា:**
ជា លាង
Brenda J. HOLLIS

**សហមេធាវីការពារក្តី យឹម ទិត្យ:**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN

ស្វូ មូស្សេទ្រី
Suzana TOMANOVIĆ

ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ

Nushin SARKARATI

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យបដិសេធសេចក្តីសម្រេច លើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី" ដែលបានដាក់ដោយសហមេធាវីការពារក្តី យឹម ទិត្យ ("សហមេធាវី") នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ "សំណើបន្ទាន់")[1]។

## I. ប្រវត្តិនីតិវិធី និងសារណា

1. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ សហមេធាវីបានដាក់ ផែនការសកម្មភាពសម្រាប់ខែកុម្ភៈ ឆ្នាំ២០២១ របស់ខ្លួន ស្របទៅតាមផ្នែក ង(៤) នៃគម្រោងជំនួយផ្នែកច្បាប់ របស់ អ.វ.ត.ក។

2. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ អង្គភាពគាំពារការការពារក្តី បានចេញសេចក្តីសម្រេចលើផែនការសកម្មភាពរបស់ខ្លួន ដោយកម្រិតចំនួនម៉ោងដែលអនុម័តថា មានភាពចំបាច់និងសមហេតុផលសម្រាប់ក្រុមមេធាវីការពារក្តី យឹម ទិត្យ ពី១៥០ម៉ោង ទៅ៧៥ម៉ោង សម្រាប់សហមេធាវីម្នាក់ៗ។ នៅក្នុងសេចក្តីសម្រេចនេះ អង្គភាពគាំពារការការពារក្តីពិចារណាថា "មិនមានសវនាការផ្ទាល់មាត់ក្នុងសំណុំរឿង ០០៤ នៅចំពោះមុខអង្គបុរេជំនុំជម្រះ" ដោយផ្អែកលើមូលដ្ឋានដែលថា ការិយាល័យរដ្ឋបាល មិនបានទទួលការជូនដំណឹងអំពីសវនការពីអង្គបុរេជំនុំជម្រះ និងដោយផ្អែកលើគម្រោងបញ្ចប់ផែនការ វិសោធនកម្មលើកទី២៧[2]។

3. នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ សហមេធាវីបានដាក់សំណើបន្ទាន់ ជាភាសាអង់គ្លេស[3] ដោយស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យច្រានចោលសេចក្តីសម្រេច លើផែនការសកម្មភាព ដែលចេញដោយអង្គភាពគាំពារការការពារក្តី កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ហើយស្នើឱ្យបង្គាប់ទៅអង្គភាពគាំពារ

---

[1] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") (អបជ ៦១) សំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យបដិសេធសេចក្តីសម្រេចលើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ D381/33 & D382/32 ("សំណើបន្ទាន់ (ឯកសារ D381/33 & D382/32)")។

[2] សំណុំរឿង ០០៤ ឯកសារភ្ជាប់៖ អ៊ីមែលរបស់អង្គភាពគាំពារការការពារក្តី ផ្ញើរជូនលោក សូ មូស្សេដ្ឋី និងលោកស្រី Suzana TOMANOVIĆ "សេចក្តីសម្រេចលើផែនការសកម្មភាព៖ ខែកុម្ភៈ ឆ្នាំ២០២១" ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ឯកសារ D381/33.1.3 & D382/32.1.3 ("សេចក្តីសម្រេចលើផែនការសកម្មភាព (ឯកសារ D381/33.1.3 & D382/32.1.3)")។

[3] សំណុំរឿង ០០៤ សំណើសុំការអនុញ្ញាតដាក់សំណើបន្ទាន់របស់ យឹម ទិត្យ ដើម្បីច្រានចោលសេចក្តីសម្រេច របស់អង្គភាពគាំពារការការពារក្តីលើផែនការសកម្មភាព តែមួយភាសា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ D381/32 & D382/31។

ការការពារក្តី ឲ្យអនុម័តភ្លាមៗលើ ផែនការសកម្មភាពរបស់សហមេធាវី សម្រាប់ខែកុម្ភៈ ឆ្នាំ ២០២១[4]។ ឯកសារបកប្រែជាភាសាខ្មែរ នៃសំណើបន្ទាន់នេះ ត្រូវបានដាក់នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០២១។

4. សហមេធាវីបានលើកឡើងថា សំណើបន្ទាន់របស់ខ្លួន គឺអាចទទួលយកបាន អនុលោមទៅតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[5] ដោយសារតែមិនមានវិធានណាមួយ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលចែង អំពីនីតិវិធីប្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសម្រេចលើផែនការសកម្មភាព[6] និងដោយសារតែមាន ភាពចាំបាច់ សម្រាប់ការធ្វើអន្តរាគមន៍ ដើម្បីជៀសវាងពីព្យសនកម្ម ដែលមិនអាចជួសជុលបាន ចំពោះយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ យឹម ទិត្យ រួមទាំងសិទ្ធិទទួលបាន ភាពជាតំណាងតាមផ្លូវច្បាប់ ប្រកបដោយប្រសិទ្ធិភាពរបស់គាត់ និងសិទ្ធិ ទទួលបានសច្ចភាពផ្លូវច្បាប់[7]។

5. អនុលោមទៅតាមការណែនាំរបស់អង្គបុរេជំនុំជម្រះ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១[8] សហព្រះរាជអាជ្ញា អន្តរជាតិ និងអង្គភាពគាំពារការការពារក្តី បានដាក់ចម្លើយតបរបស់ខ្លួន ចំពោះសំណើបន្ទាន់ នៅថ្ងៃ ទី០៤ ខែកុម្ភៈ ឆ្នាំ២០២១[9] និងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១[10]។ សហព្រះរាជអាជ្ញាជាតិ និង

---

[4] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32)។

[5] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ៤-៦។

[6] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ៧ - ១៣។

[7] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ១៤-១៧។

[8] សំណុំរឿង ០០៤ សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ ជូនទៅភាគីនានា អង្គភាពគាំពារការការពារក្តី និងការិយាល័យរដ្ឋបាល អ៊ីមែលថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១។

[9] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើបន្ទាន់របស់ យឹម ទិត្យ សុំឲ្យច្រានចោលសេចក្តីសម្រេច ស្តីពីផែនការសកម្មភាពរបស់ផ្នែកគាំពារការការពារក្តី ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ D381/34 & D382/33 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/34 & D382/33)")។

[10] សំណុំរឿង ០០៤ ចម្លើយតបរបស់អង្គភាពគាំពារការការពារក្តី ទៅនឹងសំណើរបស់ យឹម ទិត្យ សុំឲ្យបដិសេធសេចក្តីសម្រេ លើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ D381/35 & D382/34 ("ចម្លើយតបរបស់អង្គភាពគាំពារការការពារក្តី (ឯកសារ D381/35 & D382/3)")។

សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងការិយាល័យរដ្ឋបាល មិនបានឆ្លើយតបចំពោះសំណើបន្ទាន់នេះឡើយ។

6. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឡើងថា បញ្ហាអាចដោះស្រាយដោយល្អបំផុត បើអង្គបុរេជំនុំជម្រះធ្វើការជូនដំណឹងភ្លាមៗទៅភាគីថា តើនឹងមានសវនាការផ្ទាល់មាត់ដែរឬអត់[11]។

7. នៅក្នុងចម្លើយតបរបស់ខ្លួន អង្គភាពគាំពារការការពារក្ដី បានស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យបដិសេធសំណើបន្ទាន់ ហើយចាត់ចំណាត់ថ្នាក់ជាសាធារណៈ ចំពោះការដាក់ឯកសារសំខាន់ៗទាំងអស់ ពាក់ព័ន្ធនឹងបញ្ហានេះ[12]។ អង្គភាពគាំពារការការពារក្ដី បានលើកឡើងបន្ថែមថា ការធ្វើអន្តរាគមន៍ដោយអង្គបុរេជំនុំជម្រះ មិនមានការតម្រូវ និងមិនសមស្របឡើយនៅពេលនេះ ដោយសារតែ៖ (១) សហមេធាវីមិនបានប្រើប្រាស់ នីតិវិធីនៅក្នុងកិច្ចសន្យាសេវាផ្លូវច្បាប់របស់ខ្លួន[13] (២) សំណើសុំរបស់សហមេធាវី មិនអាចផ្ដល់បានដោយ អ.វ.ត.ក ទេ[14] និង (៣) សេចក្ដីសម្រេចលើផែនការសកម្មភាព ការពារសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ និងសិទ្ធិទទួលបានតំណាងផ្លូវច្បាប់ ប្រកបដោយប្រសិទ្ធិភាពរបស់ យឹម ទិត្យ[15]។

## II. ភាពអាចទទួលយកបាន

8. អង្គបុរេជំនុំជម្រះសូមរំឭកថា គោលការណ៍ជាសារវន្ត ដែលមានចែងនៅក្នុង វិធាន ២១ នៃវិធានផ្ទៃក្នុង បានឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌតម្រូវ សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ ដែល អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្ត អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត

---

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/34 & D382/33)។

[12] ចម្លើយតបរបស់អង្គភាពគាំពារការការពារក្ដី (ឯកសារ D381/35 & D382/3)។

[13] ចម្លើយតបរបស់អង្គភាពគាំពារការការពារក្ដី (ឯកសារ D381/35 & D382/3) កថាខណ្ឌ ៤ -១៣។

[14] ចម្លើយតបរបស់អង្គភាពគាំពារការការពារក្ដី (ឯកសារ D381/35 & D382/3) កថាខណ្ឌ ១៤ -១៨។

[15] ចម្លើយតបរបស់ អង្គភាពគាំពារការការពារក្ដី (ឯកសារ D381/35 & D382/3) កថាខណ្ឌ ១៩ -២៥។

អ.វ.ត.ក[16] មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[17] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ[18]។ ពាក់ព័ន្ធជាមួយបណ្តឹងឧទ្ធរណ៍ ដែលបានដាក់តាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានសម្រេចថា គោលការណ៍ដែលមានចែងក្នុងវិធាននេះ អាចតម្រូវឱ្យមានការអនុម័តយក ការបកស្រាយដោយសេរីទៅលើសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថាកិច្ចដំណើរការនីតិវិធី គឺយុត្តិធម៌និងគោរពគោលការណ៍ចំពោះមុខ[19]។ ក្នុងករណីពិសេស នៅពេលដែលអង្គហេតុឬកាលៈទេសៈពិសេសនៃសំណុំរឿង តម្រូវឱ្យអនុវត្តបែបនេះ អង្គជំនុំជម្រះអាចទទួលយកបណ្តឹងឧទ្ធរណ៍ តាមវិធាន ២១ នៃវិធានផ្ទៃក្នុងដោយផ្ទាល់ ឬតាមរយៈការបកស្រាយក្នុងន័យទូលាយ ទៅលើបទប្បញ្ញត្តិជាក់លាក់នៃវិធានផ្ទៃក្នុង ដែលផ្តល់ដល់អង្គជំនុំជម្រះ នូវយុត្តាធិការ[20]។

9. ទោះជាបែបនេះក្តី អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់ដូចគ្នាថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានបើកផ្លូវដោយស្វ័យប្រវត្តិឡើយសម្រាប់ការប្តឹងឧទ្ធរណ៍ បើទោះបីជាបណ្តឹងឧទ្ធរណ៍ លើកឡើងពីបញ្ហានៃ

---

[16] *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ចូលជាធរមានថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

[17] *ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នស/រកម/១០០៤/០០៦ វិសោធនកម្មថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[18] *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ 999 U.N.T.S. 171 និង 1057 U.N.T.S. 407 *ចូលជាធរមាន ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។*

[19] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (“សំណុំរឿង ០០៤/២”) (អបជ ៦០) សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការបន្តចរិការបស់ក្រុមមេធាវីការពារក្តីលោក អោ អាន ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D359/17 និង D360/26 (“សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (ឯកសារ D359/17 & D360/26)”) កថាខណ្ឌ ៥។ សំណុំរឿង ០០៤ (អបជ ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ (ឯកសារ D239/1/8) (“សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ អ៊ឹម ចែម ប្រឆាំងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ដោយកំបាំងមុខ (ឯកសារ D239/1/8)”) កថាខណ្ឌ ១៧។

[20] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (ឯកសារ D359/17 & D360/26) កថាខណ្ឌ ៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ដោយកំបាំងមុខ (ឯកសារ D239/1/8) កថាខណ្ឌ ១៧។ *សេចក្តីសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យបដិសេធសេចក្តីសម្រេចលើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី*

សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្តី[21]។ វិធាន២១ នៃវិធានផ្ទៃក្នុង ក៏មិនបានផ្តល់ដល់អង្គបុរេជំនុំជម្រះ នូវយុត្តាធិការក្នុងការដោះស្រាយ បញ្ហាបែបសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំឡើយ[22]។ ដើម្បីឲ្យអង្គជំនុំជម្រះ អាចពិនិត្យលើបណ្តឹងឧទ្ធរណ៍ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង បន្ទុកគឺស្ថិតលើម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការបង្ហាញថា ស្ថានភាពចំពោះមុខ គឺមិនស្ថិតក្នុងវិធានជាធរមាន ហើយថាកាលៈទេសៈជាក់ស្តែងនៃរឿងក្តី តម្រូវឲ្យមានកិច្ចអន្តរាគមន៍របស់អង្គជំនុំជម្រះ ដើម្បីជៀសវាងព្យសនកម្ម ដែលមិនអាចជួសជុលបាន សម្រាប់ភាពយុត្តិធម៌ នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍[23]។

10. នៅក្នុងករណីបច្ចុប្បន្ន អង្គបុរេជំនុំជម្រះមិនជឿជាក់ថា សហមេធាវីបានបំពេញបាន តាមលក្ខខណ្ឌតម្រូវណាមួយ សម្រាប់ភាពអាចទទួលយកបានឡើយ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ ទីមួយ ចំពោះការចោទប្រកាន់ថា មិនមានវិធានណាមួយនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលចែងអំពីនីតិវិធីក្នុងការប្តឹងឧទ្ធរណ៍សេចក្តីសម្រេចលើផែនការសកម្មភាព[24]នោះ អង្គបុរេជំនុំជម្រះយល់ឃើញផ្ទុយទៅវិញថា បញ្ហាចំពោះមុខនេះ គឺពិតជាស្ថិតនៅក្នុងវិសាលភាព នៃយន្តការដោះស្រាយជម្លោះ

---

[21] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (ឯកសារ D359/17 & D360/26) កថាខណ្ឌ ៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ អ៊ឹម ចែម ប្រឆាំងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ (ឯកសារ D239/1/8) កថាខណ្ឌ ១៧។

[22] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (ឯកសារ D359/17 & D360/26) កថាខណ្ឌ ៦។ សំណុំរឿង ០០៤ (អបជ ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ (ឯកសារ D205/1/1/2) កថាខណ្ឌ ៧-៨។

[23] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (ឯកសារ D359/17 & D360/26) កថាខណ្ឌ ៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ អ៊ឹម ចែម ប្រឆាំងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ដោយកំបាំងមុខ (ឯកសារ D239/1/8) កថាខណ្ឌ ១៧។

[24] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ៧-១៣។

ដែលមានចែងនៅក្នុងលក្ខខណ្ឌនៃគម្រោងជំនួយផ្នែកច្បាប់[25] និង/ឬ កិច្ចសន្យាសេវាផ្លូវច្បាប់របស់សហមេធាវី[26] ដែលពួកគេយល់ព្រមចងកាតព្វកិច្ច[27]។

11. អង្គជំនុំជម្រះកត់សម្គាល់ថា យន្តការដោះស្រាយជម្លោះ តាមផ្នែក ច(៩) និង ច(១០) នៃគម្រោងជំនួយផ្នែកច្បាប់ និងផ្នែក ១១.២ និង១១.៣ នៃកិច្ចសន្យាសេវាផ្លូវច្បាប់ របស់សហមេធាវី មិនអាចអនុវត្តបានឡើយ ក្នុងកាលៈទេសៈដែលសេចក្តីសម្រេចទាមទារកម្រៃ មិនទាន់ត្រូវបានធ្វើឡើងនោះ[28]។ បន្ថែមលើនេះ អង្គជំនុំជម្រះសូមរំឭកថា អង្គជំនុំជម្រះមិនផ្តល់មតិយោបល់ណែនាំឡើយ ហើយរាល់ជម្លោះណាមួយពាក់ព័ន្ធនឹងសេចក្តីសម្រេចស្តាពរ លើការទូទាត់កម្រៃ អាចត្រូវបានលើកឡើងតាមនីតិវិធីពាក់ព័ន្ធនៅដំណាក់កាលក្រោយ[29]។

12. ទោះជាបែបនេះក្តី អង្គបុរេជំនុំជម្រះពិចារណាថា សហមេធាវីមិនបានស្វែងរក ឬប្រើប្រាស់ឲ្យអស់លទ្ធភាព នូវយន្តការដោះស្រាយជម្លោះ ដែលមានស្រាប់សម្រាប់ខ្លួន នៅពេលវេលាពាក់ព័ន្ធឡើយ។ តាមផ្នែក១១.១ នៃកិច្ចសន្យាសេវាផ្លូវច្បាប់ សហមេធាវីមានកាតព្វកិច្ច ដោះស្រាយដោយការយោគយល់ "ទំនាស់ ការខ្វែងយោបល់គ្នា ឬការទាមទារនានា" ពាក់ព័ន្ធលក្ខខណ្ឌនៃកិច្ចសន្យារបស់

---

[25] គម្រោងជំនួយផ្នែកច្បាប់ អ.វ.ត.ក ខែធ្នូ ឆ្នាំ២០១៤ (វិសោធនកម្ម) ឯកសារ D381/33.1.1 & D382/32.1.1។

[26] សំណុំរឿង ០០៤ ឯកសារភ្ជាប់៖ កិច្ចសន្យាសេវាផ្លូវច្បាប់រវាង លោកសូ មូស្សេនី និងលោកស្រី Suzana TOMANOVIĆ ជាមួយអង្គភាពគាំពារការការពារក្តី, ឯកសារភ្ជាប់ជាមួយសំណើបន្ទាន់របស់ យឹម ទិត្យ សុំឲ្យបដិសេធសេចក្តីសម្រេច លើផែនការសកម្មភាពរបស់ អង្គភាពគាំពារការការពារក្តី ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ D381/33.1.4 & D382/32.1.4 ("កិច្ចសន្យាសេវាផ្លូវច្បាប់ (ឯកសារ D381/33.1.4 & D382/32.1.4)") ផ្នែក ១១។ *សូមមើលផងដែរ* ចម្លើយតបរបស់ អង្គភាពគាំពារការការពារក្តី (ឯកសារ D381/35 & D382/3)) ជើងទំព័រ ១២ (កត់សម្គាល់ថាពាក្យពេចន៍ នៅផ្នែកដែលពាក់ព័ន្ធ របស់កិច្ចសន្យាសេវាផ្លូវច្បាប់របស់លោក សូ មូស្សេនី គឺដូចគ្នានឹងពាក្យពេចន៍ នៅក្នុងកិច្ចសន្យាលោកស្រី Tomanović)។

[27] កិច្ចសន្យាសេវាផ្លូវច្បាប់ (ឯកសារ D381/33.1.4 & D382/32.1.4)។

[28] កិច្ចសន្យាសេវាផ្លូវច្បាប់ (ឯកសារ D381/33.1.4 & D382/32.1.4)។ អង្គបុរេជំនុំជម្រះចាត់ទុកថា ជាការមិនចាំបាច់ក្នុងការកំណត់ប្រភេទ ទំនាស់ដែលពាក់ព័ន្ធសេចក្តីសម្រេច លើផែនការសកម្មភាព ថាជាជម្លោះ "មិនពាក់ព័ន្ធកម្រៃ" ឬ "កម្រៃ" ដោយពិចារណាថា មានផ្លូវដ៏ច្បាស់លាស់សម្រាប់ការដោះស្រាយទំនាស់ សម្រាប់ប្រភេទទំនាស់នីមួយៗ។

[29] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (ឯកសារ D359/17 & D360/26) កថាខណ្ឌ ៦, ១០។

ខ្លួន[30]។ ក្នុងករណីដែលភាគីមិនអាចដោះស្រាយដោយការយោគយល់គ្នា នូវទំនាស់របស់ខ្លួន ក្នុងរយៈពេល៦០ថ្ងៃ ទំនាស់នោះអាចត្រូវបានបញ្ជូនទៅចៅក្រមរដ្ឋបាលអង្គការសហប្រជាជាតិ[31]។

13. ជាក់លាក់ជាងនេះទៅទៀត អង្គជំនុំជម្រះមិនជឿជាក់ លើការអះអាងរបស់សហមេធាវីដែលថា នីតិវិធីដោះស្រាយជម្លោះកិច្ចសន្យានេះ មិនអាចប្រើប្រាស់បាន បន្ទាប់ពីចេញសេចក្តីសម្រេច លើផែនការសកម្មភាពឡើយ[32] ហើយអង្គជំនុំជម្រះកត់សម្គាល់ការលើកឡើងរបស់អង្គភាពគាំពារការការពារក្តីដែលថា "យើងនូវតែផ្តល់ឱកាសឲ្យសហមេធាវី ដើម្បីជួបជាមួយអង្គភាពគាំពារការការពារក្តី" ដោយមានចេតនាដោះស្រាយបញ្ហាដោយការយោគយល់[33]។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា សហមេធាវីមិនបានបង្ហាញឲ្យបានគ្រប់គ្រាន់ថា ឧបាស្រ័យជាមួយចៅក្រមរដ្ឋបាលអង្គការសហប្រជាជាតិ មិនបានផ្តល់នូវការជួសជុល ប្រកបដោយប្រសិទ្ធិភាពនោះទេ[34] និងពិចារណាថា ការធានានៅក្នុងក្របខណ្ឌគតិយុត្តិបច្ចុប្បន្ន គឺគ្រប់គ្រាន់ដើម្បីធានាដល់ការគោរព សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌របស់ យឹម ទិត្យ[35]។

14. ទីពីរ ចំពោះការអះអាងដែលថា សេចក្តីសម្រេចលើផែនការសកម្មភាព បណ្តាលឲ្យមានព្យសនកម្មមិនអាចជួសជុលបាន ចំពោះភាពយុត្តិធម៌នៃ កិច្ចដំណើរការនីតិវិធី[36] អង្គជំនុំជម្រះកត់សម្គាល់ថា ការចោទប្រកាន់នេះគឺផ្អែកលើ តម្រូវការធនធានរបស់សហមេធាវី ដើម្បីត្រៀមរៀបចំដោយគ្រប់គ្រាន់សម្រាប់សវនាការផ្ទាល់មាត់ ក្នុងសំណុំរឿង០០៤[37]។ បន្ទាប់ពីបានពិចារណាទៅលើមតិរបស់

---

[30] កិច្ចសន្យាសេវាផ្លូវច្បាប់ (ឯកសារ D381/33.1.4 & D382/32.1.4) ផ្នែក ១១.១។

[31] កិច្ចសន្យាសេវាផ្លូវច្បាប់ (ឯកសារ D381/33.1.4 & D382/32.1.4) ផ្នែក ១១.១។

[32] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ១២។

[33] ចម្លើយតបរបស់ អង្គភាពគាំពារការការពារក្តី (ឯកសារ D381/35 & D382/3)) កថាខណ្ឌ ៦។

[34] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ១២-១៣។

[35] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (ឯកសារ D359/17 & D360/26) កថាខណ្ឌ ៨ ("អង្គជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន ១១(២)(៣) និងវិធាន ១១(២)(ជ) នៃវិធានផ្ទៃក្នុង អង្គភាពគាំពារការការពារក្តី ជាអ្នកពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត កិច្ចសន្យាការងាររបស់សហមេធាវីជាមួយជនជាប់ចោទ និងអនុញ្ញាតឲ្យផ្តល់ប្រាក់កម្រៃ ទៅតាមគម្រោងជំនួយផ្នែកច្បាប់ ជាបទបញ្ជារដ្ឋបាលមួយ ដែលត្រូវអនុម័តទៅតាមវិធាន ៤ នៃវិធានផ្ទៃក្នុង")។

[36] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ១៤-១៧ (រួមទាំងសិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបាន ភាពជាតំណាងផ្លូវច្បាប់ ប្រកបដោយប្រសិទ្ធិភាព និងសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់)។

[37] សំណើបន្ទាន់ (ឯកសារ D381/33 & D382/32) កថាខណ្ឌ ១៥-១៦។

ភាគីនានា[38] អង្គបុរេជំនុំជម្រះសម្រេចដោយអនុលោមទៅតាម វិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង បន្ទនីតិវិធីនិងធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤ ផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[39]។

15. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចថា សហមេធាវីខកខានមិនបានបង្ហាញថា ស្ថានភាពចំពោះមុខ មិនស្ថិតក្នុងវិធានជាធរមាន ឬថា តម្រូវឲ្យមានកិច្ចអន្តរាគមន៍របស់អង្គជំនុំជម្រះ ដើម្បីជៀសវាងព្យសនកម្មមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបាន ការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ យឹម ទិត្យ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា សំណើបន្ទាន់នេះមិនអាចទទួលយកបានឡើយ។

16. ទោះជាបែបនេះក្តី អង្គបុរេជំនុំជម្រះពិចារណាថា មានភាពពាក់ព័ន្ធក្នុងការពិភាក្សាលើកំហុសឆ្គងមួយចំនួន នៅក្នុងយុត្តិកម្មរបស់អង្គភាពគាំពារការការពារក្តី សម្រាប់ការកាត់បន្ថយ កម្រិតអតិបរមាសម្រាប់ការទូទាត់ ពី១៥០ម៉ោង ទៅ៧៥ម៉ោង។ ជាពិសេស អង្គជំនុំជម្រះកត់សម្គាល់ចំពោះការពឹងផ្អែកដោយខុសរបស់អង្គភាពគាំពារការការពារក្តី ទៅលើគម្រោងបញ្ចប់ផែនការបច្ចុប្បន្ន និងព័ត៌មានដែលបានទទួលពីការិយាល័យរដ្ឋបាល ដែលផ្តល់នូវមតិបែបទាយស្មានថា មិនមានសវនាការក្នុងសំណុំរឿង ០០៤[40]។ អង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា

---

[38] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសវនាការផ្ទាល់មាត់ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (យឹម ទិត្យ) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/36 & D382/35។ សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងសវនាការផ្ទាល់មាត់ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ អ៊ីមែល ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/40 & D382/39។ សារណារបស់ យឹម ទិត្យ ជូនអង្គបុរេជំនុំជម្រះ ស្តីពីភាពចាំបាច់សម្រាប់សវនាការផ្ទាល់មាត់ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/38 & D382/37។ មតិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លើសវនាការផ្ទាល់មាត់ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/39 & D382/38។

[39] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសវនាការផ្ទាល់មាត់ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/41 & D382/42

[40] សេចក្តីសម្រេចលើផែនការសកម្មភាព (ឯកសារ D381/33.1.3 & D382/32.1.3) នៅត្រង់ ERN 01663089 កថាខណ្ឌ ២។ ចម្លើយតបរបស់ អង្គភាពគាំពារការការពារក្តី (ឯកសារ D381/35 & D382/3)) កថាខណ្ឌ ២២ (១១-១៤)។ សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ៧៖ អ៊ីមែលរបស់ការិយាល័យរដ្ឋបាល ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ជាឧបសម្ព័ន្ធជាមួយចម្លើយតប

*សេចក្តីសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឲ្យបដិសេធសេចក្តីសម្រេច*

*លើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី*

នេះគឺជាសមត្ថកិច្ចផ្តាច់មុខ របស់អង្គបុរេជំនុំជម្រះ ក្នុងការសម្រេចថាមានឬមិនមានសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤។ គម្រោងបញ្ចប់ផែនការ និងមតិរបស់ការិយាល័យរដ្ឋបាល លើបញ្ហានេះ មិនអាចជាកត្តាកំណត់ក្នុងការណែនាំដល់យុត្តិកម្មរបស់អង្គភាពគាំពារការការពារក្តី សម្រាប់ការកាត់បន្ថយចំនួនម៉ោង ដែលត្រូវអនុម័តនៅក្នុងសេចក្តីសម្រេចលើផែនការសកម្មភាពនោះឡើយ។

17. បន្ថែមលើនេះ អង្គជំនុំជម្រះពិចារណាថា ជាការមិនសមស្របឡើយ ចំពោះការយោងរបស់អង្គភាពគាំពារការការពារក្តី ទៅលើតម្រូវការក្នុងការធ្វើឱ្យមាន "តុល្យភាព" រវាងសិទ្ធិជនជាប់ចោទ និងការគ្រប់គ្រងមូលនិធិសាធារណៈដោយតម្លាភាព[41] ក្នុងករណីដែលការណ៍នេះសំដៅថា ការពិចារណាលើថវិកា អាចត្រូវថ្លឹងថ្លែងធៀបនិងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានភាពជាតំណាងផ្លូវច្បាប់ប្រកបដោយប្រសិទ្ធិភាព។ អង្គជំនុំជម្រះរំឭកថា កាតព្វកិច្ចរបស់អង្គភាពគាំពារការការពារក្តី អនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង ក្នុងការបកស្រាយបទបញ្ជារដ្ឋបាលជាធរមាន គឺត្រូវតែការពារផលប្រយោជន៍ជនជាប់ចោទ ដែលដូច្នេះហើយអង្គជំនុំជម្រះទទូចដល់អង្គភាពគាំពារការការពារក្តី ឱ្យបែងចែកធនធានផ្អែកលើកត្តាចាំបាច់និងសមហេតុផល សម្រាប់ការការពារក្តីប្រកបដោយប្រសិទ្ធិភាពរបស់ យឹម ទិត្យ។

## III. ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធ** សំណើបន្ទាន់ ដោយសារមិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២១**

---

របស់អង្គភាពគាំពារការការពារក្តី ទៅនឹងសំណើរបស់ យឹម ទិត្យ សុំឱ្យបដិសេធសេចក្តីសម្រេច លើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ D381/35.1.7 & D382/34.1.7។

[41] សេចក្តីសម្រេចលើផែនការសកម្មភាព (ឯកសារ D381/33.1.3 & D382/32.1.3) នៅត្រង់ ERN 01663089 ចម្លើយតបរបស់អង្គភាពគាំពារការការពារក្តី (ឯកសារ D381/35 & D382/3) កថាខណ្ឌ ២០។

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី ធុល** **Kang Jin BAIK** **ហួត វុទ្ធី**